ENTERPRISE CHALLENGE FUND
for the Pacific and South East Asia
GROWING BUSINESS TO REDUCE POVERTY

**AUSTRALIAN EMBASSY**
**PHNOM PENH**

**Embargoed until: 11.30am 29 April 2009**

# Australia supports financial literacy and savings in rural Cambodia
# ប្រទេសអូស្ត្រាលីគាំទ្រការយល់ដឹងពីសេវាហិរញ្ញវត្ថុ និង ការសន្សំនៅតាមតំបន់ជនបទក្នុងប្រទេសកម្ពុជា

**Phnom Penh:** Australia's Ambassador to Cambodia, Margaret Adamson, today presented mobile phone payment service provider, WING, with a A$1.5 million (US$975,000) grant which will help support financial literacy, income opportunities and provide millions of dollars worth of savings for Cambodians living in rural areas.

**ភ្នំពេញៈ** ថ្ងៃនេះលោកស្រី Margaret Adamson ដែលជាឯកអគ្គរាជទូតប្រទេសអូស្ត្រាលីប្រចាំនៅប្រទេសកម្ពុជាបានធ្វើការផ្តល់ជូនក្រុមហ៊ុន WING ដែលជាក្រុមហ៊ុនផ្តល់សេវាកម្មទូទាត់ប្រាក់តាមរយៈទូរស័ព្ទដៃ នូវជំនួយជាសាច់ប្រាក់ចំនួន ១.៥ លានដុល្លាអូស្ត្រាលី (ស្មើនឹង ៩៧៥០០០ ដុល្លាអាមេរិក) ដើម្បីជួយគាំទ្រនូវការយល់ដឹងពីសេវាហិរញ្ញវត្ថុ ឱកាសរកប្រាក់ចំណូល ហើយនឹងផ្តល់នូវអត្ថប្រយោជន៍សន្សំសំចៃដែលមានតំលៃរាប់លានដុល្លាសំរាប់ប្រជាជនកម្ពុជាដែលរស់នៅតាមតំបន់ដាច់ស្រយាល។

Ms Adamson said providing access to employment and markets and encouraging the growth of small businesses in developing countries was vital in order to achieve a meaningful and sustainable reduction in poverty.

លោកស្រី Adamson មានប្រសាសន៍ថាការផ្តល់នូវឱកាសការងារនិងទីផ្សារ និងការជំរុញនូវការអភិវឌ្ឍន៍នៃជំនួញខ្នាតតូចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍គឺមានសារៈសំខាន់ណាស់ក្នុងការសំរេចបាននូវការកាត់បន្ថយភាពក្រីក្រដោយទទួលបានលទ្ធផលខ្ពស់។

"Through the Enterprise Challenge Fund (ECF), the Australian Government is helping the private sector to play its part in alleviating poverty across the Asia-Pacific region," Ms Adamson said.

លោកស្រីបានមានប្រសាសន៍ថា រដ្ឋាភិបាលអូស្ត្រាលីកំពុងជួយក្រុមហ៊ុនឯកជនដើម្បីចូលរួមចំនែកក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក តាមរយៈមូលនិធិសហគ្រាសឯកជន (ECF) ។

Australia's support for WING, through the ECF, is estimated to provide about 8 million rural Cambodians with access to affordable and convenient banking services.

ជំនួយរបស់មូលនិធិសហគ្រាសឯកជនដល់ក្រុមហ៊ុន WING តាមរយៈ ECF ត្រូវបានប៉ាន់ស្មានថានឹងអាចជួយផ្តល់លទ្ធភាពដល់ប្រជាជនកម្ពុជានៅតាមតំបន់ជនបទប្រមាណ ៨លាននាក់ ក្នុងការប្រើប្រាស់សេវាកម្មធនាគាដែលសមស្របនិងអាចទទួលយកបាន។

Many rural Cambodians' livelihoods depend on money sent home from family members working in urban areas. Current options for transferring funds, including by courier or in person, make this process expensive, time consuming and often dangerous.


Villa 11, R.V. Senei Vinnavaut Oum (Former St 254), Chaktaumuk Quarter, Daun Penh District, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

ជីវភាពប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាភាគច្រើនពឹងផ្អែកលើប្រាក់ផ្ញើរមកផ្ទះដោយសមាជិកគ្រួសារដែលកំពុងធ្វើការនៅតំបន់ទីក្រុង។ ជំរើសក្នុងការផ្ទេរប្រាក់សព្វថ្ងៃ (រាប់បញ្ចូលទាំងការផ្ញើរឬយកទៅដោយផ្ទាល់) មានតំលៃថ្លៃ ចំណាយពេលវេលាច្រើន ហើយមានគ្រោះថ្នាក់ជាញឹកញាប់។

With the support of the Australian Government, WING will be able to extend its financial services including person-to-person payments, money transfers and pre-paid purchases to rural Cambodians. The WING service, which uses mobile phone technology, has the potential to deliver savings of US$3 million per year in transaction costs[1] for every 100,000 rural Cambodians with access to WING.

ដោយមានការគាំទ្រពីរដ្ឋាភិបាលអូស្រ្តាលី WING នឹងមានលទ្ធភាពពង្រីកសេវាកម្មហិរញ្ញវត្ថុរបស់ខ្លួនទៅដល់ប្រជាជនកម្ពុជានៅតាមបំបន់ដាច់ស្រយាល ដោយរួមបញ្ចូលទាំងការផ្ញើរប្រាក់ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ការផ្ទេរប្រាក់ ការទិញទំនិញជាដើម។ សេវាកម្ម WING (ដែលប្រើប្រាស់បច្ចេកវិជ្ជាទូរស័ព្ទចល័ត) មានសក្តានុពលក្នុងការសន្សំសំចៃបានចំនួនប្រមាណ៣លានដុល្លាក្នុងមួយឆ្នាំក្នុងការចំនាយលើការធ្វើប្រតិបត្តការផ្ញើរប្រាក់សំរាប់ប្រជាជនកម្ពុជាតាមតំបន់ដាច់ស្រយាលចំនួន១០០០០០នាក់ ជាមួយនឹងការប្រើប្រាស់សេវាកម្ម WING ។

WING Managing Director, Mr Brad Jones, said: “The WING mobile phone payment service has great potential to create jobs and alleviate poverty by helping Cambodian people in under privileged communities build savings, develop financial literacy and gain access vital goods and services. We’re pleased to have the support of the Australian Government‘s Enterprise Challenge Fund to be able to extend the service to rural areas where we would otherwise not have operated.”

លោក Brad Jones ដែលជាអគ្គនាយករបស់ WING បានមានប្រសាសន៍ថា សេវាកម្មទូទាត់ប្រាក់តាមរយៈទូរស័ព្ទចល័តរបស់ WING មានសក្តានុពលជាច្រើនក្នុងការបង្កើតការងារ និង កាត់បន្ថយភាពក្រីក្រ ដោយការជួយប្រជាជនកម្ពុជានៅក្នុងសហគមន៍ដែលមានឯកសិទ្ធ បង្កើតការសន្សំប្រាក់ អភិវឌ្ឍន៍ការយល់ដឹងផ្នែកហិរញ្ញវត្ថុ និងទទួលបានលទ្ធភាពប្រើប្រាស់សេវាកម្មនិងទំនិញសំខាន់ៗនានា។ ពួកយើងសប្បាយរីករាយដែលមានការគាំទ្រពីមូលនិធិសហគ្រាសឯកជនសំរាប់ការចាប់ផ្តើមជំនួញរបស់រដ្ឋាភិបាលអូស្រ្តាលី ដែលអាចធ្វើ អោយយើងពង្រីកសេវាកម្មនៅតាមតំបន់ជនបទបាន ហើយបើមិនមានជំនួយនេះទេ ពួកយើងមិនអាចមានលទ្ធភាពធ្វើដូច្នោះឡើយ។

---

[1] Calculated based on each transaction currently costing US$3. With WING’s service costing 0.50¢, the savings per transaction is US$3.00 – 0.50¢ = US$2.50. Therefore, if WING’s service is used once a month, 100,000 receivers x 12 months x $2.50 = US$3 million in savings.



Villa 11, R.V. Senei Vinnavaut Oum (Former St 254), Chaktaumuk Quarter, Daun Penh District, Phnom Penh City, Kingdom of Cambodia

Telephone: 855 23 213470 Facsimile: 855 23 213413

ECF promotes private sector investment in initiatives that extend services or provide employment and other benefits to poor communities. It provides grants of between $100,000 and $1.5 million for commercially sustainable projects where businesses are prepared to at least match the Australian Government’s grant. The Fund closely monitors the projects ensuring they adhere to the terms of the grant.

មូលនិធិសហគ្រាសឯកជន ECF ធ្វើការជ្រោមជ្រែងលើការផ្តួចផ្តើមការធ្វើវិនិយោគរបស់ក្រុមហ៊ុនឯកជនដែលពង្រីកសេវាកម្ម ឬផ្តល់ការងារ និងអត្ថប្រយោជន៍ ផ្សេងៗទៀតដល់សហគមន៍ក្រីក្រ។ ECF ផ្តល់ដើមទុនពី ១០០០០០ ដុល្លាទៅ ១.៥លានដុល្លា សំរាប់គំរោងពាណិជ្ជកម្មដែលមាន

ស្ថេរភាពហើយស្របជាមួយនេះដែរក្រុមហ៊ុនត្រូវមានគំរោងលើការវិនិយោគយ៉ាងហោចណាស់ត្រូវសមស្របទៅនិងជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី។ ប្រាក់ឧបត្ថម្ភត្រូវបានត្រួតពិនិត្យយ៉ាងម៉តចត់ធ្វើយ៉ាងណាដើម្បីប្រាកដថាពួកគេគោរពតាមល័ក្ខខ័ណ្ឌរបស់ជំនួយយ៉ាងខ្ជាប់ខ្ជួន។

WING is a wholly owned subsidiary of Australia and New Zealand Banking Group (ANZ), one of only 11 long-term AA (Standard & Poors) rated banks in the world. WING works with Vision Fund, a micro finance institution owned by World Vision, to deliver the service as well as the International Finance Corporation’s Access to Finance program to measure the social and economic benefits of the WING program.

WING គឺជាក្រុមហ៊ុនដែលទទួលការទំនុកបំរុងទាំងស្រុងពីធនាគារ ANZ ដែលជាធនាគារមួយក្នុងចំនោមធនាគារដែលជាប់ចំនាត់ថ្នាក់ទាំង១១នៅលើពិភពលោក។ WING ធ្វើការជាមួយ Vision Fund ដែលជាស្ថាប័នមីក្រូហិរញ្ញវត្ថុមួយដែលបង្កើតឡើងដោយអង្គការទស្សនៈពិភពលោក ដើម្បីចូលរួមចំនែកក្នុងការផ្តល់សេវាកម្មនិងលទ្ធភាពចូលទៅកាន់កម្មវិធីហិរញ្ញវត្ថុរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដើម្បីវាស់វែងអត្ថប្រយោជន៍ផ្នែកសង្គមនិងសេដ្ឋកិច្ចនៃកម្មវិធី WING។

**Media enquiries:**

Lachlan Pontifex
Enterprise Challenge Fund / AusAID
Telephone:+85 (0)12 900 911

May Meere
Communications Manager, South & South East Asia
Tel: +65 6216 1884
Cell: +65 9726 7923


Villa 11, R.V. Senei Vinnavaut Oum (Former St 254), Chaktaumuk Quarter, Daun Penh District, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413